# ដំណាំត្រសក់ស្រូវ

## ១-ការរៀបចំដី និងធ្វើរង

- សំអាតដីចំការ ជ្រើសរើសស្មៅនិងកាកសំណល់ដំណាំចាស់អោយស្អាត
- ភ្ជួររាស់ដីអោយបានហ្មត់ល្អហើយហាលអោយបាន១០-១៥ថ្ងៃ(ភ្ជួរ៣-៤ដង)។
- បាចកំបោរស និងជីធម្មជាតិរួចភ្ជួររាស់លប់
- ភ្ជួរដី(គោក្របីរឺគោយន្ត)ជម្រៅ១៥-២០សង់ទីម៉ែត្រ ។

ការលើករងៈ

-ទទឹងរង១,៥០ម៉ែត្រ និងបណ្តោយតាមលទ្ធភាពដី តែមិនគួរអោយលើសពី ១៥ម៉ែត្រ ដែលធ្វើអោយពិបាកក្នុងការថែទាំ ដូចជា ស្រោចទឹក ដកស្មៅជាដើម ។

-កំពស់ៈ នៅរដូវប្រាំងពី២០-៣០សង់ទីម៉ែត្រ និងរដូវវស្សាពី៣០-៥០សង់ទីម៉ែត្រ។

-ដាក់ជីលាមកសត្វស្ងួតរឺជីកំប៉ុស្តិ៍ ក្នុងបរិមាណពី១-២គីឡូក្រាម/ម$^2$កប់ទ្រាប់ បាតរង ដោយច្របល់វាអោយសព្វល្អជាមួយដី។

-ការគ្របរងៈ ធ្វើបានពីរប្រភេទ ដើម្បីទប់ទល់ការហូរច្រោះដី រក្សាសំណើមដី កាត់បន្ថយការដុះស្មៅ និងរក្សាជីជាតិដីអោយបានល្អ ។

**ក-ការធ្វើរងប្រើប្លាស្ទិចគ្របដី**

- ក្រោយពីលើករងរួចហើយយើងត្រូវចាប់ផ្តើមគ្របប្លាស់ស្ទិចពណ៌ទឹកប្រាក់ដាក់ខាងលើ និងពណ៌ខ្មៅដាក់ខាងក្រោម ៖

-ប្រើបន្ទះឬស្សីស្រួចសំរាប់ខ្ទាស់ជើងរងប្លាស់ស្ទិច។

-ដោតឬស្សីនៅសងខាងជើងរងប្រវែងពី១៥-២០សង់ទីម៉ែត្រ

-យកដីសង្កត់ជើងរងសងខាង

-ចោះរណ្តៅដោយប្រើកំប៉ុងដាក់រងើកភ្លើង

១-ប្រើខ្សែទាញតំរង់ ដើម្បីចោះរណ្តៅដាំកូន និងប្រើខ្នាតសំរាប់ចោះរណ្តៅ ពីគុម្ពមួយទៅគុម្ពមួយ

២-ប្រើកំប៉ុងដាក់រងើកភ្លើង សំរាប់ចោះរណ្តៅ

៣-រៀបចំបបង្គោលសំណាញ់ទ្រើង អោយហើយ ។

**ខ-ការគ្របរងដោយប្រើចំបើងៈ**

- ក្រោយពីលើករងរួចហើយយើងត្រូវចាប់ផ្តើមគ្របចំបើងដើម្បីការពារកុំអោយដីឆាប់ស្ងួត ការពារការហូរច្រោះដី កាត់បន្ថយការដុះស្មៅ និងជួយរក្សាសំណើមក្នុងដី។រៀបចំបបង្គោលសំណាញ់ទ្រើង អោយហើយ ។

## ២-ការធ្វើរានបណ្តុះកូន

ការធ្វើរានបណ្តុះកូន គឺអាចធ្វើអោយគ្រាប់ដុះបានល្អ កាត់បន្ថយការលួយកូន និងអាចការពារកូនដំណាំបានពីការឆ្លងជម្ងឺ ពីសត្វល្អិតចង្រៃ(ដែលមកយាយីកូនដំណាំ) ។ រោងបណ្តុះកូនបន្លែអាចធ្វើតាមទំហំខាងក្រោម ៖

- កំពស់រោងសំរាប់គ្របរានៈ កំពស់១,៨-២ម៉ែត្រដើម្បីងាយស្រួល ចេញចូលថែទាំ។

- កំពស់រានៈ ពី០,៨-១ម៉ែត្រពីដីមកកូនដំណាំ។
- ប្រក់ដំបូលការពារទឹកភ្លៀង និងសំណាញ់ការពារពន្លឺថ្ងៃ(ជាការប្រសើរប្រើសំណាញ់ពណ៌បៃតង)
- មានជញ្ជាំងធ្វើពីសំណាញ់មុងពណ៌ស ការពារសត្វល្អិត ។

## ៣-ការរៀបចំដីបណ្តុះកូន

ដំបូងយកដីមានជីជាតិ១ភាគលាយជាមួយលាមកគោឬជីកំប៉ុស្តិ៍២ភាគបូកជាមួយអំពុកចំបើងឬស្រកីដូង២ភាគ និងធ្យូងអង្កាម២ភាគ (ធ្យូងអង្កាមត្រូវត្រាំទឹក២ទៅ៣យប់) យកល្បាយដែលបានរៀបចំរួចមកច្របល់ ចូលគ្នាអោយសព្វល្អ ហើយយកទៅលីងលើភ្លើងរយៈពេល៣០-៤៥នាទីដោយអោយមានកំដៅប្រហែល៨០អង្សាសេ។

- **ផលប្រយោជន៍នៃការលោយល្បាយ សំរាប់បណ្តុះកូនៈ**
  - ✓ គ្រាប់ងាយដុះ ឬសដុះលូតលាស់ល្អ
  - ✓ កូនបន្លែស្រូបយកជីជាតិបានគ្រប់គ្រាន់
  - ✓ សម្លាប់គ្រាប់ស្មៅមិនអោយដុះដណ្តើមជីជាតិពីកូនបន្លែ
  - ✓ សម្លាប់មេរោគ (ជម្ងឺ)ដែលបង្កអោយកូនបន្លែរលួយ
  - ✓ សម្លាប់ពងសត្វល្អិត និងសត្វល្អិតចង្រៃក្នុងដីដែលបំផ្លាញគ្រាប់បន្លែ
- **យកដីដែលលីងទុកអោយត្រជាក់សិន ទើបដាក់ក្នុងថាស់បណ្តុះ**

វិធីរៀបចំលាយល្បាយដាក់ថាសបណ្តុះ





## ៤-ការរៀបចំបណ្តុះកូនត្រសក់ទ្រើង

- ○ ត្រូវរៀបចំបណ្តុះគ្រាប់ ព្រមពេលជាមួយគ្នានិងការលើករងដាំ
- ○ ការបណ្តុះកូនត្រសក់

-យកគ្រាប់១គ្រាប់ដាក់ក្នុងថាស់បណ្តុះឬរន្ធបណ្តុះ១គ្រាប់

-រោយដីល្បាយកំរាស់១សង់ទីម៉ែត្រ(កន្លះថ្នាំងដៃ)ពីលើគ្រាប់

-បាញ់ទឹកអោយជោគលើថាស់បណ្តុះហើយទើបយកថាស់នោះទៅផ្អាប់ក្នុង ថង់ពណ៌ខ្មៅរយៈពេល២យប់សិនទើបយកថាស់មកដាក់លើរានបណ្តុះ

-បាញ់ទឹក១ថ្ងៃ៣-៤ដង អាស្រ័យតាមស្ថានភាពដីក្នុងថាស់។





## ៥-ការដាំកូនត្រសក់ស្រូវ

- កូនត្រសក់អាយុ៧ថ្ងៃ បន្ទាប់ពីដុះគ្រាប់ហើយអាចយកទៅដាំបាន ។ បន្ទាប់ពីគ្រាប់ដុះបាន៣ថ្ងៃត្រូវយកកូនត្រសក់ទៅដាក់អោយត្រូវពន្លឺថ្ងៃ និងកាត់បន្ថយការ ស្រោចទឹកដើម្បីពង្រឹងកូន មុនពេលដាំ (មិនស្រពោនបន្ទាប់ពីដាំ) ។
- ដាក់ជីទ្រាប់បាតមុនដាំច្របល់ជាមួយដីអោយបានសព្វ(បើបានដាក់ជីមុនគ្របប្លាស្ទិចហើយ មិនបាច់ដាក់ជីទៀតទេ) ។
- បញ្ចូលទឹកតាមរងដាំគ្របប្លាស្ទិច (បើស្រោចដោយដៃក្នុងរណ្តៅរងគ្របប្លាស្ទិច អាចបណ្តាល អោយកូនបន្លែស្វិតស្រពោន)ឬស្រោចទឹកលើរងដែលគ្របចំបើង ។
- របៀបដកកូនបន្លែចេញពីថាស់បណ្តុះគឺយកម្រាមដៃរុញបាតថាស់ឡើងលើ ហើយដៃម្ខាងទៀតដកកូនដំណាំថ្នមៗដើម្បីកុំអោយដាច់ឫស ។
- ដាំកូនត្រសក់នៅពេលរសៀល





## ៦-ការថែទាំ៖

- ការដាក់ជីគីមីបំប៉ន:

ពូជត្រសក់បង្កាត់(អ៊ីប្រីដ)ត្រូវដាក់ជីគីមី និងស្រោចទឹកឲ្យទៀងទាត់ ទើបផ្តល់ផ្លែផ្កាបានច្រើន។ ពេលវេលានិងបរិមាណជីដែលត្រូវដាក់ អាស្រ័យតាមប្រភេទដី ។ ដាក់ជីបំប៉នឲ្យបានទៀងទាត់រៀង រាល់ ៧ថ្ងៃម្តង បន្ទាប់ពីដាំកូនបន្លែហើយ ។ ចំពោះដីខ្សាច់ ត្រូវដាក់ជីឲ្យញឹកញាប់ តែក្នុង បរិមាណតិចជាងដីដែលមានល្បាយច្រើនជាងខ្សាច់ ។

**បរិមាណ និងពេលវេលានៃការដាក់ជីសំរាប់ត្រសក់ពូជបង្កាត់**

| ពេលវេលាដាក់ជី | ប្រភេទជី | បរិមាណជី | ទីកន្លែងដាក់ជី |
|---|---|---|---|
| មុនដាំ១៥ថ្ងៃ | លាមកសត្វ ជីកំប៉ុស្ត | ១-២គីឡូក្រាម/$m^2$ | បុកកប់កណ្ដាលរណ្ដៅលើរង |
| មុនដាំ៥-៧ថ្ងៃ បន្ទាប់ពីចោះរង | ជី២០.២០.១៥ | ៥ក្រាម/គុម្ពឬ១គម្របដបទឹកសុទ្ធ | បុកកប់កណ្ដាលរណ្ដៅលើរងមុន ដាំ៥-៧ថ្ងៃ |
| ក្រោយដាំកូន៧ថ្ងៃ | ជី ៤៦.០.០ | ៥ក្រាម/គុម្ពឬ១គម្របដបទឹកសុទ្ធ | កប់ជីសងខាង គុម្ពចំងាយ ១៥សង់ទីម៉ែត្រ |
| ក្រោយដាំកូន១៤ថ្ងៃ | ជី២០.២០.១៥ | ៥ក្រាម/គុម្ព មួយរន្ធ១គគុម្ព | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្រ |
| ក្រោយដាំកូន ១៨-១៩ថ្ងៃ | ជីបំប៉នបាញ់លើស្លឹក(ជី៣០.៥.៥) | ៥០ក្រាម/ទឹក១៦លីត្រ (ជី៥០០ម^២) | បាញ់លើស្លឹក និងដើម |
| ក្រោយដាំកូន២១ថ្ងៃ | ជី២០.២០.១៥ | ៥ក្រាម/គុម្ព មួយរន្ធ១គគុម្ព | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្រ |
| ក្រោយដាំកូន ២៨-៣០ថ្ងៃ | ជី០.០.៦០ឬ ជីបំប៉នបាញ់ស្លឹក (ជី១១.៩.៤០) | ៥ក្រាម/គុម្ព ៥០ក្រាម/ទឹក១៦លីត្រ (ជី៥០០ម^២) | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្របាញ់លើសលើ ស្លឹក ដើម ផ្កា |
| ក្រោយដាំកូន ៣៥ថ្ងៃ | ជី០.០.៦០ជី ជី១៦.២០.០ | ៥ក្រាម/គុម្ព | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្រ |
| ក្រោយដាំកូន ៤៥ថ្ងៃ | ជី០.០.៦០ ជី១៦.២០.០ | ៥ក្រាម/គុម្ព | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្រ |
| ក្រោយដាំកូន ៥០-៥៥ថ្ងៃ | ជី០.០.៦០ ជី១៦.២០.០ បំប៉នផ្កា ផ្លែ (ជី១១.៩.៤០) | ៥ក្រាម/គុម្ព ៥០ក្រាម/ទឹក១៦លីត្រ (ជី៥០០ម^២) | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្រ បាញ់លើសលើ ស្លឹក ដើម ផ្កា |
| ក្រោយដាំកូន ៦០ថ្ងៃ | ជី០.០.៦០ | ៥ក្រាម/គុម្ព | កប់ជីសងខាង គុម្ពចំងាយ ១៨-២៥សង់ទីម៉ែត្រ |
| ចំណាំ៖ ជី១០ក្រាម(ប្រហែល១ស្លាបព្រាបាយ)និង៥ក្រាម(ប្រហែលកន្លះស្លាប ព្រាបាយឬ១គម្របដបទឹកសុទ្ធតូច)។ | | | |